ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ពេលព្រះជាម្ចាស់បាន បង្កើតរបស់គ្រប់យ៉ាង



និពន្ធដោយ៖ Edward Hughes
ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus
Alastair Paterson
កែសម្រួលដោយ៖ Bob Davies; Tammy S.
បកប្រែដោយ៖ www.christian-translation.com
ផលិតដោយ៖ Bible for Children
www.M1914.org

BFC
PO Box 3
Winnipeg, MB R3C 2G1
Canada

©2020 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

តើនរណាបង្កើតយើងឡើង? សៀវភៅព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះប្រាប់ពីរបៀបដែលមនុស្សជាតិបានចាប់កំណើតឡើង។ កាលពីយូរលង់ណាស់មកហើយ ព្រះទ្រង់បានបង្កើតមនុស្សដំបូងបង្អស់ម្នាក់ ហើយដាក់ឈ្មោះគាត់ថា អាដាម។



ព្រះទ្រង់បានបង្កើតអាដាមចេញពីធូលីដី។ ទ្រង់បានប្រទាន
ជីវិតដល់អាដាម ហើយគេក៏អាចរស់រានមានជីវិតឡើង។
គាត់បានរស់នៅក្នុងសួនដ៏ស្រស់ស្អាតមួយឈ្មោះថាអ៊ីដែន។



មុនពេលព្រះទ្រង់បង្កើតអាដាម, ទ្រង់បានបង្កើតពិភពលោកដ៏ស្រស់ស្អាតដែលពោរពេញទៅដោយរបស់អស្ចារ្យ។ ម្តងបន្តិចៗ ព្រះទ្រង់បានបង្កើតតំបន់ភ្នំ និងទីវាលធំល្វឹងល្វើយ, ផ្កាដ៏ក្រអូប និងដើមឈើខ្ពស់ៗ, បក្សាបក្សីដែលមានរោមស្រស់ស្អាត និងហ្វូងឃ្មុំលាន់ទ្រហឹង, ត្រីបាឡែនធំៗ និងខ្យងដែលពោរពេញដោយភាពរអិល។ តាមពិតទៅ,



ព្រះទ្រង់បានបង្កើតគ្រប់យ៉ាងនៅទីនោះ គឺគ្រប់យ៉ាង។

ដំបូងឡើយ មុនពេលព្រះបានបង្កើត
គ្រប់យ៉ាង លើលោកនេះមិនមានអ្វី
ឡើយ ក្រៅពីទ្រង់។ គ្មានមនុស្សម្នា
ឬទីកន្លែង ឬរបស់អ្វីឡើយ។
គ្មានអ្វីសោះឡើយ។
គ្មានពន្លឺ
ហើយក៏គ្មានភាព
ងងឹតដែរ។ គ្មានលើ
ហើយក៏គ្មានក្រោម។
គ្មានម្សិលមិញ គ្មានថ្ងៃស្អែ
ក។ មានតែព្រះជាម្ចាស់តែ
ប៉ុណ្ណោះដែលគ្មានការចាប់ផ្ដើម។
ក្រោយមក ព្រះទ្រង់បានធ្វើ
សកម្មភាព! ដំបូង ទ្រង់បាន
បង្កើតឋានសួគ៌ និងផែនដី។



ហើយផែនដីគ្មានទ្រង់ទ្រាយ ហើយ
ទទេរស្អាត។ ហើយភាព
ងងឹតគ្របដណ្ដប់លើ
ជម្រៅទឹក។
ក្រោយមក
ព្រះមានព្រះ
បន្ទូលថា
“ចូរមាន
ពន្លឺឡើង”។



ហើយពន្លឺក៏កើតមានឡើងតាមបន្ទូលរបស់ទ្រង់។ ព្រះទ្រង់ហៅពន្លឺថាថ្ងៃ ហើយភាពងងឹតថាជាយប់។ ហើយក៏មានពេលល្ងាច និងពេលព្រឹកជាថ្ងៃទីមួយ។



នៅថ្ងៃទីពីរ ព្រះទ្រង់បាននាំយកទឹកមហាសមុទ្រ, ទឹកសមុទ្រ និងបឹងបួរដាក់តាមលំដាប់នៅក្រោមផ្ទៃមេឃ។ នៅថ្ងៃទីបី, ព្រះបានមានព្រះបន្ទូលថា “ចូរមានដីស្ងួតលេចឡើង” ហើយវាក៏កើតមានឡើងតាមបន្ទូលរបស់ទ្រង់។



ព្រះទ្រង់ក៏បានបញ្ជាអោយស្មៅ, ផ្កា និងគុម្ពព្រៃ និងដើម
ឈើលេចឡើង។ ហើយពួកវាក៏បានលេចឡើង
បន្ទាប់មកក៏មានពេលល្ងាច
និងពេលព្រឹកឡើង
ជាថ្ងៃទីបី។



បន្ទាប់មក ទ្រង់បានបង្កើតព្រះ
អាទិត្យ និងព្រះចន្ទ និងផ្កាយជា
ច្រើនដែលគ្មាននរណាម្នាក់អាចរាប់
អស់ឡើយ។ ហើយក៏មានពេលល្ងាច
និងពេលព្រឹកឡើងជាថ្ងៃទីបួន។



សត្វនៅក្នុងសមុទ្រ ហើយនឹងត្រី
ព្រមទាំងបក្សាបក្សីស្ថិតនៅក្នុង
បញ្ជីបន្ទាប់របស់ព្រះ។ នៅថ្ងៃទី
ប្រាំ ទ្រង់បានបង្កើតត្រីមាត់ដាវ
ធំៗ និងត្រីតូចៗជាច្រើន, ព្រម
ទាំងសត្វអូទ្រីសដែលមានជើងវែ
ងៗ និងសត្វស្លាបតូចៗដែល
ស្រែកច្រៀងយ៉ាងពិរោះ។ ព្រះ
បានបង្កើតគ្រប់ប្រភេទត្រី
ដើម្បីបំពេញក្នុងទឹក ហើយនឹង
គ្រប់ប្រភេទបក្សាបក្សីអោយ
កំសាន្តសប្បាយនៅលើដី, ក្នុងស
មុទ្រ និងនៅលើអាកាស។ ហើយ
ក៏មានពេលល្ងាច និងពេលព្រឹក
ឡើងជាថ្ងៃទីប្រាំ។



បន្ទាប់ពីនោះមក ព្រះបានមានបន្ទូលម្តងទៀតថា “សូមអោយផែនដីបង្កើតអោយមានជីវិតរស់នៅទីបួន...” សត្វគ្រប់ប្រភេទ, សត្វល្អិត និងពពួកសត្វលូនបានមានជីវិតឡើង។ ហើយក៏មានសត្វដំរីដ៏ធំសម្បើមដែលអាចដើរអោយរញ្ជួយដី សត្វភេដែលតែងតែរវល់ ព្រមទាំងសត្វស្វាក្រមិចក្រមើម និងសត្វក្រពើល្វីល្វើ ហើយក៏មានដង្កូវរួចខ្លួន និងសត្វកំប្រុកថ្គាល់ប៉ោង, សត្វកវែង និងសត្វឆ្មាដែលស្រមុកខុលៗ។ សត្វគ្រប់ប្រភេទត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់នៅថ្ងៃនោះ។ ហើយក៏មានពេលល្ងាច និងពេលព្រឹកឡើងជាថ្ងៃទីប្រាំមួយ។



ព្រះទ្រង់បានបង្កើតអ្វីមួយទៀតនៅថ្ងៃទីប្រាំមួយនឹង អ្វី ម៉្យាងដែលពិសេសខ្លាំង។ ពេលនេះគ្រប់យ៉ាងត្រៀមជាស្រេច សំរាប់មនុស្ស។ មានចំនីអាហារនៅទីវាល និងមានសត្វនៅ ចាំបម្រើគេ។ ហើយព្រះជាម្ចាស់បានមានបន្ទូលថា “ចូរអោ យមនុស្សមានរូបរាងដូចជារូប យើង។ សូមអោយគេជាម្ចាស់លើ គ្រប់យ៉ាងដែលមានលើផែនដីនេះ។” ដូច្នេះព្រះជាម្ចាស់បានបង្កើត មនុស្សក្នុងរូបភាពផ្ទាល់ របស់ទ្រង់, នៅក្នុងរូបភាព របស់ទ្រង់ ទ្រង់បាន បង្កើតគាត់...



ព្រះបានមានព្រះ
បន្ទូលទៅអាដាម
ថា “បរិភោគនូវ
អ្វីដែលអែងចង់
ពីក្នុងសួនបាន
លើកលែងតែ
ដើមដឹងខុសត្រូ
វ។ ប្រសិនបើអែង
បរិភោគពីដើម
នោះ អែង
ប្រាកដជាស្លាប់
ជាមិនខាន។”



ហើយព្រះបានមានបន្ទូលថា “វាមិនល្អទ្បើយដែលមនុស្សនៅឯការម្នាក់ឯង។ យើងនឹងបង្កើតជំនួយម្នាក់ដល់គេ។” ទ្រង់បាននាំយកនូវសត្វបក្សាបក្សី និងសត្វសាហាវគ្រប់ប្រភេទ ទៅអោយអាដាម។ អាដាមបានដាក់ឈ្មោះអោយពួកសត្វទាំងនោះ។ អាដាមប្រាកដជាឆ្លាតណាស់ហើយដែលអាចធ្វើរឿងនឹងបាន។ ប៉ុន្តែក្នុងចំណោមសត្វទាំងអស់នោះ មិនមានសត្វមួយណាដែលសាកសមជាដៃគូរជាមួយអាដាមទ្បើយ។



ព្រះជាម្ចាស់បានធ្វើអោយអាដាមដេកលង់លក់ស្កប់ស្កល់ ហើយទ្រង់បានដកយកឆ្អឹងជំនីមួយពីអាដាម ទ្រង់បានបង្កើតស្ត្រីម្នាក់ពីឆ្អឹងជំនីអាដាម។ ស្ត្រីដែលព្រះជាម្ចាស់បានបង្កើតល្អសាកសមជាដៃគូររបស់អាដាមពិតមែន។



ព្រះទ្រង់បានបង្កើតគ្រប់យ៉ាងក្នុងពេលប្រាំមួយ
ថ្ងៃ។ បន្ទាប់មក ព្រះជាម្ចាស់បានអោយពរដល់
ថ្ងៃទីប្រាំពីរ ហើយបានយកវាធ្វើជាថ្ងៃសំរាក។ នៅ
ក្នុងសួនអ៊ីដែន អាដាម និងភរិយារបស់គាត់,
អ៊ីវ មានសុភមង្គលល្អឥតទាស់គ្រាប់បង្គាប់
របស់ព្រះ។ ព្រះ ជាម្ចាស់របស់ពួកគេ,
ជាអ្នកផ្តល់ទំនុកបម្រុងដល់ពួកគេ
និងជាមិត្តរបស់ពួកគេ។



ពេលព្រះជាម្ចាស់បានបង្កើតរបស់គ្រប់យ៉ាង

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

លោកុប្បត្តិ ១-២

“ការបើកសម្ដែងនូវព្រះបន្ទូលទ្រង់ផ្តល់នូវពន្លឺ។”
ទំនុកតម្កើង ១១៩៖ ១៣០

ចប់

1

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្លេះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាមែន។

សូមអានព្រះគុម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ! យូហាន ៣៖១៦